ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ ថក ២២/២០២៦ កបទ.សអ

សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យ
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
កម្ពុជាបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តចំពោះការសន្ទនាដោយសន្តិវិធី
និងការគោរពច្បាប់អន្តរជាតិ ក្នុងការដោះស្រាយស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ

អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានកត់សម្គាល់សេចក្តីថ្លែងការណ៍ដែលចេញផ្សាយដោយក្រសួងការបរទេសថៃ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៦ ទាក់ទងនឹងការចូលរួមរបស់ថៃក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនី លើកទី៤៨ (CMF) និងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ ដែលបានប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៦។ ក្នុងន័យនេះ កម្ពុជាសូមធ្វើការបំភ្លឺ ដូចខាងក្រោម ៖

ទី១. កម្ពុជាបដិសេធយ៉ាងដាច់ខាតចំពោះការចោទប្រកាន់ថា កម្ពុជាបានប្រើប្រាស់កិច្ចប្រជុំទាំងនេះដើម្បីបង្ខូចកេរ្តិ៍ឈ្មោះថៃ ឬផ្សព្វផ្សាយនិទានរឿងតែម្ខាង។ ការលើកឡើងរបស់កម្ពុជាអំពីស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ មានបំណងទាញចំណាប់អារម្មណ៍លើការវិវត្តន៍នៅលើដី និងផលវិបាកមនុស្សធម៌ ព្រមទាំងសង្កត់ធ្ងន់លើសារៈសំខាន់នៃការសន្ទនា ការបន្ធូរភាពតានតឹង និងការដោះស្រាយវិវាទដោយសន្តិវិធី។ គោលបំណងទាំងនេះ ស្របតាមគោលការណ៍របស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (OIF) និងមូលបទនៃកិច្ចប្រជុំកំពូលលើកទី២០ គឺ "រួមគ្នាបន្តកសាងសន្តិភាព ដើម្បីវិបុលភាពរួម និងស្ថិរភាពយូរអង្វែង"។

ទី២. ក្នុងនាមជាម្ចាស់ផ្ទះ និងជាប្រធានកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ កម្ពុជាបានបំពេញការទទួលខុសត្រូវរបស់ខ្លួនដោយភាពមិនលំអៀង តម្លាភាព និងការគោរពច្បាប់ និងនីតិវិធីរបស់អង្គការ OIF ។ កម្ពុជាក្នុងនាមជាសមាជិកពេញសិទ្ធិរបស់ OIF មានសិទ្ធិស្របច្បាប់ក្នុងការសម្តែងនូវកង្វល់របស់ខ្លួនលើបញ្ហាដែលប៉ះពាល់ដល់អធិបតេយ្យ បូរណភាពទឹកដី និងសុខុមាលភាពរបស់ប្រជាជន។ ការចូលរួមបែបនេះ មិនគួរត្រូវបានយល់ខុសថា ជាការប៉ុនប៉ងធ្វើឱ្យខូចទំនាក់ទំនងទ្វេភាគី ឬកិច្ចខិតខំប្រឹងប្រែងដែលកំពុងបន្តដើម្បីដោះស្រាយការវិវាទដោយសន្តិវិធីឡើយ។

ទី៣. កង្វល់របស់កម្ពុជាទាក់ទងនឹងស្ថានការណ៍ព្រំដែន គឺផ្អែកលើការវិវត្តន៍ដែលប៉ះពាល់ដល់ដី និងប្រជាជនរបស់ខ្លួន។ ការវិវត្តន៍ទាំងនេះរួមមាន ការប៉ះទង្គិចប្រដាប់អាវុធរវាងប្រទេសទាំងពីរ វត្តមាននៃកងកម្លាំងប្រដាប់អាវុធថៃនៅក្នុងតំបន់ដែលកម្ពុជាចាត់ទុកថាស្ថិតក្នុងដែនអធិបតេយ្យរបស់ខ្លួន បន្ទាប់ពីបទឈប់បាញ់នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ការខូចខាតដល់បេតិកភណ្ឌវប្បធម៌កម្ពុជា និងការផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋភៀសសឹកកម្ពុជាប្រមាណ ២០,០០០ នាក់ ដែលនៅតែមិនអាចវិលត្រឡប់ទៅ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

ផ្ទះសំបែង និងប្រកបមុខរបររបស់ពួកគាត់វិញ។ កង្វល់មនុស្សធម៌ និងសន្តិសុខដ៏ធ្ងន់ធ្ងរទាំងនេះ មិនអាចត្រូវបានបដិសេធថាជាការចោទប្រកាន់គ្មានមូលដ្ឋានឡើយ។

ទី៤. ចំពោះការលើកឡើងរបស់ថៃអំពីកាលៈទេសៈប្រវត្តិសាស្ត្រនៃសហគមន៍កម្ពុជានៅតំបន់ព្រំដែន កម្ពុជារក្សាជំហរថា ការទាមទារទឹកដីដែលខុសគ្នា ត្រូវតែដោះស្រាយតាមរយៈយន្តការទ្វេភាគីដែលមានស្រាប់ និងស្របតាមច្បាប់អន្តរជាតិ។ កម្ពុជាសូមអំពាវនាវជាថ្មីឱ្យបន្តឡើងវិញ ដោយមិនពន្យារពេល នៃការងារគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក (JBC) ដើម្បីពិនិត្យស្ថានការណ៍ជាក់ស្តែង និងជំរុញការកំណត់ព្រំដែនស្របតាមកិច្ចព្រមព្រៀងដែលមានស្រាប់។

ទី៥. កម្ពុជាបានកត់សម្គាល់ការលើកឡើងរបស់ថៃអំពីវិធានការកសាងទំនុកចិត្តដែលបានពិភាក្សានៅខែតុលា ឆ្នាំ២០២៦ និងការព្រមព្រៀងគ្នាដែលសម្រេចបានដោយនាយករដ្ឋមន្ត្រីទាំងពីរ នៅស៊ីប៊ូ ក្នុងខែឧសភា ឆ្នាំ២០២៦។ កម្ពុជាបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តចំពោះកិច្ចខិតខំប្រឹងប្រែងទាំងនេះ និងចំពោះការអនុវត្តពេញលេញ និងមានប្រសិទ្ធភាពនៃសេចក្តីប្រកាសរួមនៃកិច្ចប្រជុំពិសេសរបស់គណៈកម្មការព្រំដែនទូទៅ (GBC) នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។ ការស្តារទំនុកចិត្តគ្នាទៅវិញទៅមកតម្រូវឱ្យមានសកម្មភាពជាក់ស្តែង ការគោរពការប្តេជ្ញាដែលបានព្រមព្រៀងគ្នា និងការបង្កលក្ខខណ្ឌអំណោយផលសម្រាប់ការវិលត្រឡប់ដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរបស់ជនភៀសសឹកស៊ីវិល។

ទី៦. កម្ពុជាបដិសេធយ៉ាងដាច់អហង្ការចំពោះការចោទប្រកាន់ថា កម្ពុជាជាប្រធានអង្គប្រជុំ មានចេតនាមិនផ្តល់ឱកាសឱ្យថៃបានថ្លែងសេចក្តីក្នុងអំឡុងពេលសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនីលើកទី៤៨។ ដោយសារកិច្ចប្រជុំនេះប្រព្រឹត្តទៅយឺតពេលជាងកាលវិភាគកំណត់ជាងពីរម៉ោង កម្ពុជាជាប្រធានអង្គប្រជុំដោយបានពិគ្រោះយោបល់ជាមួយលេខាធិការដ្ឋានអង្គការ OIF បានឯកភាពផ្តល់អាទិភាពថ្លែងសេចក្តីដល់អ្នកសង្កេតការណ៍ដែលមានតំណាងក្នុងកម្រិតរដ្ឋមន្ត្រី។ អ្នកផ្សេងទៀតត្រូវបានអញ្ជើញឱ្យដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ដើម្បីបញ្ចូលក្នុងកំណត់ត្រាផ្លូវការនៃកិច្ចប្រជុំ។ ការរៀបចំនេះ បានអនុវត្តដូចៗគ្នាចំពោះគណៈប្រតិភូពាក់ព័ន្ធទាំងអស់ ដោយមិនមែនផ្តោតទៅលើគណៈប្រតិភូថៃនោះឡើយ។

ជាចុងក្រោយ កម្ពុជានៅតែប្តេជ្ញាយ៉ាងមុតមាំក្នុងការដោះស្រាយវិវាទរបស់ខ្លួនជាមួយថៃ តាមរយៈការសន្ទនា ការទូត និងមធ្យោបាយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន។ កម្ពុជាត្រៀមខ្លួនជាស្រេចក្នុងការសហការប្រកបដោយស្ថាបនាជាមួយថៃ តាមរយៈយន្តការទ្វេភាគីដែលមានស្រាប់ ដើម្បីស្តារទំនុកចិត្តគ្នាទៅវិញទៅមក ធានាការគោរពអធិបតេយ្យ និងបូរណភាពទឹកដី និងសម្រេចបានសន្តិភាព និងស្ថិរភាពយូរអង្វែងនៅតាមបណ្តោយព្រំដែនរួមរបស់ប្រទេសទាំងពីរ។

កម្ពុជាជឿជាក់យ៉ាងមុតមាំថា ភាពជាអ្នកជិតខាងល្អពិតប្រាកដ ត្រូវតែមានមូលដ្ឋានលើការគោរពគ្នាទៅវិញទៅមក ការអនុវត្តដោយស្មោះត្រង់នូវការប្តេជ្ញាដែលបានព្រមព្រៀងគ្នា និងការការពារសុវត្ថិភាព និងសុខុមាលភាពរបស់ប្រជាជននៅសងខាងព្រំដែន។

ថ្ងៃអង្គារ ៨កើត ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៦